**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៥៥៥....សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការដាក់ឱ្យដំណើរការប្រើប្រាស់
## ប្រព័ន្ធទារយកថ្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីទទួលបន្ទុក**
**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលស្ថាប័នមានសមត្ថកិច្ចត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ដើម្បីសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ដើម្បីទទួលព័ត៌មានអ្នកដំណើរជាមុន និងកត់ត្រាឈ្មោះអ្នកដំណើរចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម។ រាល់ទិន្នន័យបុគ្គលរបស់អ្នកដំណើរតាមផ្លូវអាកាស ត្រូវបានរក្សាជាការសម្ងាត់។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅកំណត់តួនាទីនិងភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធ ក្នុងការអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាសដើម្បី៖

១. ទទួលព័ត៌មានជាមុន ដើម្បីវិភាគលើហានិភ័យការងារសំខាន់ៗមួយចំនួន ដូចជា បទល្មើសវត់គេចពន្ធគ្រប់ប្រភេទ ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនឆ្លងដែនជាដើម

២. ចូលរួមរក្សាសន្តិសុខនិងសុវត្ថិភាពអាកាសចរស៊ីវិល និងការធ្វើដំណើរតាមផ្លូវអាកាស

៣. សម្រួលសេវាកម្មឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព នៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិ និងការពារសុវត្ថិភាពជូនដល់អ្នកដំណើរតាមផ្លូវអាកាស

៤. ធ្វើឱ្យប្រសើរឡើងនូវដំណើរការត្រួតពិនិត្យការឆ្លងដែន នៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិ

៥. អនុវត្តតាមស្តង់ដារនិងអនុសាសន៍នៃអង្គការគយពិភពលោក និងអង្គការអាកាសចរស៊ីវិលអន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពបទល្មើសឆ្លងដែនគ្រប់ប្រភេទ នៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកដំណើរជនជាតិខ្មែរនិងបរទេស ដែលធ្វើដំណើរតាមផ្លូវអាកាស ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសចេញ-ចូលតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រកាសនេះ មិនអនុវត្តចំពោះអ្នកដំណើរជនជាតិខ្មែរ និងបរទេស តាមរយៈកម្មវិធីហោះហើរបន្ទាន់ជាលក្ខណៈការទូត យោធា រដ្ឋាភិបាល មនុស្សធម៌ បណ្តុះបណ្តាលហោះហើរ ឬការប្តូរជើងហោះហើរបន្ទាន់ដោយបញ្ហាបច្ចេកទេស ឬអាកាសធាតុ និងក្រុមបុគ្គលិកហោះហើរ នៃក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរឯកជនពាណិជ្ជកម្ម។

**ប្រការ ៤.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

- ដឹកនាំគ្រប់គ្រងរួម លើការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ដើម្បីអនុវត្តប្រព័ន្ធទទួលព័ត៌មានអ្នកដំណើរជាមុន និងប្រព័ន្ធកត់ត្រាឈ្មោះអ្នកដំណើរ

- សហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កំណត់នីតិវិធីនៃការអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ដើម្បីគាំទ្រដំណើរការប្រព័ន្ធទទួលព័ត៌មានអ្នកដំណើរជាមុន និងប្រព័ន្ធកត់ត្រាឈ្មោះអ្នកដំណើរ ដោយអនុលោមតាមស្តង់ដាររបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ - អង្គការគយពិភពលោក (United Nations Agency - World Customs Organization)។
- សហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល លើការគ្រប់គ្រងប្រព័ន្ធព័ត៌មាន វិភាគទិន្នន័យអ្នកដំណើរអន្តរជាតិតាមផ្លូវអាកាស ស្របតាមតួនាទីនិងភារកិច្ចដែលអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សហការជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់វិធានការចាំបាច់នានា ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ ៥.-**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានតួនាទីនិងភារកិច្ច ដូចខាងក្រោម÷

- សហការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ កំណត់នីតិវិធីនៃការអនុវត្តដល់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្តល់ទិន្នន័យអ្នកដំណើរតាមផ្លូវអាកាស ដើម្បីគាំទ្រដំណើរការប្រព័ន្ធទទួលព័ត៌មានអ្នកដំណើរជាមុន និងប្រព័ន្ធកត់ត្រាឈ្មោះអ្នកដំណើរ អនុលោមតាមស្តង់ដាររបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិ - អង្គការអាកាសចរស៊ីវិលអន្តរជាតិ (United Nations Agency - International Civil Aviation Organization)
- ដឹកនាំនិងរៀបចំផ្សព្វផ្សាយព័ត៌មានអាកាសចរ ស្តីពីការចាប់ផ្តើមដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ជូនដល់អង្គការអាកាសចរស៊ីវិលអន្តរជាតិ អាជ្ញាធរអាកាសចរស៊ីវិល នៃបណ្តាប្រទេសដែលមានកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ ក្រុមហ៊ុនហោះហើរឯកជនពាណិជ្ជកម្ម ទីភ្នាក់ងារទេសចរណ៍ អាកាសយានដ្ឋានអន្តរជាតិ និងទីភ្នាក់ងារផ្សេងៗទៀត តាមការចាំបាច់

- សហការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ លើការគ្រប់គ្រងប្រព័ន្ធព័ត៌មាន វិភាគទិន្នន័យអ្នកដំណើរអន្តរជាតិតាមផ្លូវអាកាស ស្របតាមតួនាទីនិងភារកិច្ចដែលអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សហការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់វិធានការចាំបាច់នានា ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៦.-**

ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចប្រមូលនិងផ្តល់ព័ត៌មានមុនពេលមកដល់របស់អ្នកដំណើរ និងការចេញដំណើររបស់អ្នកដំណើរ រួមទាំងទិន្នន័យអ្នកដំណើរនៃជើងហោះហើរអន្តរជាតិនីមួយៗដល់ស្ថាប័នមានសមត្ថកិច្ច ស្របតាមសេចក្តីណែនាំអនុវត្តរបស់ក្រុមការងារអន្តរក្រសួង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ប្រការ ៧.-**

រាល់ការចំណាយនៃការដាក់ឱ្យដំណើរការប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា។ រាល់ការចំណាយពាក់ព័ន្ធនឹងការធ្វើសន្ទានកម្មប្រព័ន្ធរបស់ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ជាបន្ទុករបស់ក្រុមហ៊ុនសាមី។

ការអនុវត្តប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស ពុំតម្រូវឱ្យមានការប្រមូលកម្រៃសេវាពីអ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិ ឬក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្មឡើយ។

**ប្រការ ៨.-**

ប្រកាសអន្តរក្រសួងស្តីពីការដាក់ឱ្យដំណើរការប្រើប្រាស់ប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ និងក្រុមហ៊ុនហោះហើរជាលក្ខណៈឯកជនពាណិជ្ជកម្ម ដែលមានប្រតិបត្តិការហោះហើរជាអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីទទួលបន្ទុក**
**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ